ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ១៩៤ សភ.ខល

# សេចក្តីប្រកាសព័ត៌មាន

យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** លើរបាយការណ៍ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២២ របស់គណៈប្រចាំការ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមជូនដំណឹងពីការកែសម្រួលលក្ខខណ្ឌតម្រូវឱ្យធ្វើចត្តាឡីស័ក ចំពោះអ្នកដំណើរមកពីបរទេសដែលពុំទាន់បានចាក់ ឬបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានមិនទាន់បានពេញលេញ ដូចខាងក្រោម៖

១-លើកលែងលក្ខខណ្ឌតម្រូវឱ្យធ្វើចត្តាឡីស័ក ចំពោះអ្នកដំណើរមកពីបរទេសដែលពុំទាន់បានចាក់ ឬបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានមិនទាន់បានពេញលេញ ប៉ុន្តែតម្រូវឱ្យយកសំណាកធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយមន្ត្រីសុខាភិបាល នៅតាមច្រកទ្វារចេញ-ចូលប្រទេស នៅពេលមកដល់កម្ពុជា។

- ក្នុងករណីលទ្ធផលតេស្តរហ័សអវិជ្ជមាន អ្នកដំណើរត្រូវបានអនុញ្ញាតឱ្យបន្តដំណើរទៅលំនៅឋាន ឬទៅកាន់គោលដៅរៀងៗខ្លួនដោយពុំជាប់កាតព្វកិច្ចចត្តាឡីស័ក។
- ក្នុងករណីលទ្ធផលតេស្តរហ័សវិជ្ជមានហើយជាករណីជំងឺស្រាល ចំពោះអ្នកដំណើរដែលមានលំនៅឋានសមរម្យ អាចដាក់ខ្លួនដាច់ដោយឡែកធ្វើការព្យាបាលនៅលំនៅឋានរបស់ខ្លួន។ ចំពោះអ្នកដំណើរដែលពុំមានទីតាំងស្នាក់នៅសមស្រប ត្រូវដាក់ខ្លួនដាច់ដោយឡែកធ្វើការព្យាបាលនៅទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។ អ្នកដំណើរដែលជាករណីជំងឺស្រាលត្រូវធ្វើការព្យាបាល ត្រូវអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ហើយរាល់ការចំណាយក្នុងការស្នាក់នៅព្យាបាលជាបន្ទុករបស់សាមីបុគ្គល។ ចំពោះករណីជំងឺធ្ងន់ ត្រូវទៅទទួលការព្យាបាលនៅផ្នែកព្យាបាលជំងឺកូវីដ-១៩ នៅតាមមន្ទីរពេទ្យ ដែលសេវាព្យាបាលជំងឺកូវីដ-១៩ ត្រូវបានធ្វើសមាហរណកម្មចូលក្នុងប្រព័ន្ធសុខាភិបាលតែមួយ។ ចំពោះអ្នកជំងឺកូវីដ-១៩ ជាជនបរទេសត្រូវទូទាត់ចំណាយក្នុងការស្នាក់នៅព្យាបាលដោយខ្លួនឯង។

២-អ្នកដំណើរជាជនបរទេសដែលត្រូវធ្វើតេស្តរហ័សនៅពេលមកដល់កម្ពុជា ត្រូវបង់ថ្លៃសេវាធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំនួន ៥ដុល្លារសហរដ្ឋអាមេរិក ក្នុង១នាក់ និងត្រូវអនុវត្តទៅតាមប្រកាសអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣-អ្នកដំណើរដែលខកខានពុំបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ឬដូសជំរុញ ដោយកត្តានានាដែលពុំមែនជាលក្ខខណ្ឌហាមចាក់ដោយសារកត្តាសុខភាព ត្រូវបានលើកទឹកចិត្តឱ្យប្រញាប់ទៅចាក់វ៉ាក់សាំងនៅតាមទីកន្លែងចាក់វ៉ាក់សាំងដែលមាននៅតាមរាជធានី-ខេត្ត ដោយពុំតម្រូវឱ្យបង់ប្រាក់នោះទេ។

ទោះបីជាមានការកែសម្រួលលក្ខខណ្ឌតម្រូវឱ្យធ្វើចត្តាឡីស័ក ដូចមានចែងខាងលើនេះក៏ដោយ ក្រសួងសុខាភិបាលសូមលើកទឹកចិត្តដល់អ្នកដំណើរទាំងអស់ គប្បីមានការប្រុងប្រយ័ត្ន និងបន្តអនុវត្តនូវវិធានការ ៣ការពារ ៣កុំ និងតាមដានសុខភាពខ្លួនឯងឱ្យបានខ្ជាប់ខ្ជួន ចៀសវាងការចម្លងវីរុសកូវីដ-១៩ ជាយថាហេតុ។

សេចក្តីប្រកាសព័ត៌មាននេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ តទៅ។

ថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ
- អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេសនិងការធ្វើចត្តាឡីស័ក
- រដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ